ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 25 / 06 / 2012
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

002/19-09-2007-ECCC/TC
E1/83

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ព្រហស្បត្តិ៍ ទី ០៧ ខែ មិថុនា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី - ថ្ងៃទី ៧១

រៀបចំដោយ: សែ កុលវុឌ្ឍី និង Matteo CRIPPA

| **កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ** |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូ អុត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ដាវ អានសាន, លោកស្រី Natacha WEXELS-RISER, លោកស្រី សែ កុលវុឌ្ឍី, លោក Matteo CRIPPA. |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង ប៊ុនឃាង, លោក ចាន់ ដារាវុទ្ធិ, លោក Vincent de WILDE |

| |
|---|
| D'ESTMAEL, លោក Dale LYSAK. |
| ជនជាប់ចោទ៖ អៀង សារី (ពីបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការ), នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Jasper PAUW, លោក Michiel PESTMAN |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KARNAVAS |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោក Arthur VERCKEN |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, លោក ឡោ ជុនធី, លោក គីម ម៉េងឃី, លោក វ៉ែន ពៅ, លោកស្រី ទី ស្រីនណា, លោក សំ សុគង់, លោក ហុង គឹមសួន, លោក Barnabé NEKUIE. |
| សាក្សី៖ លោក សៅ សារុន TCW-604 និង លោក ខឹម ងន TCW-323 |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖ កញ្ញា Zuzana KOVALOVA, លោក លឹម ប៊ុនហេង (មេធាវីប្រឹក្សាសាក្សី សៅ សារុន), លោក ម៉ម រិទ្ធា (មេធាវីប្រឹក្សាសាក្សី ខឹម ងន) |

**ពេលវេលាទូទៅរបស់តុលាការ៖**

| | | |
|---|---|---|
| ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ០៩.០០ | បញ្ចប់ម៉ោង៖ ១៦.០០ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៣០ | បញ្ចប់ម៉ោង៖ ១០.៥០ |
| សម្រាកអាហារថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.០៥ | បញ្ចប់ម៉ោង៖១៣.៣០ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤៥ | បញ្ចប់ម៉ោង៖ ១៥.០៥ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០៤ ម៉ោង និង ៥៥ នាទី | | |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| សេចក្តីសម្រេចនៃការជំនួសចៅក្រមជំនុំជម្រះ | អង្គជំនុំជម្រះ | ០៩.០១ | ០៩.០២ |
| សំណើសុំលះបង់សិទ្ធិចូលរួមដំណើរការសវនាការដោយផ្ទាល់ | មេធាវីការពារក្តី អៀង សារី<br>មេធាវីការពារក្តី នួន ជា | ០៩.០៣<br>១២.០៣ | ០៩.០៣<br>១២.០៣ |

| | | | |
|---|---|---|---|
| ការកែតម្រូវកាលវិភាគនៃការធ្វើសវនាការ | អង្គជំនុំជម្រះ | ០៩.០៦ | ០៩.០៦ |
| ការបន្តតាំងសំណួរទៅសាក្សី សៅ សារុន TCW-604 | សហព្រះរាជអាជ្ញា | ០៩.០៧ | ១២.០០ |
| ភាពខុសគ្នាអំពីខ្សែអាត់សម្លេង និងកំណត់ហេតុស្តាប់ចម្លើយសាក្សី និងសំណើសុំធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ | មេធាវីការពារក្តី ខៀវ សំផន<br>មេធាវីការពារក្តី នួន ជា | ១១.៤៣<br>១២.០២<br>១៣.៣៣ | ១១.៤៦<br>១២.០៣<br>១៣.៣៨ |
| ការតាំងសំណួរទៅសាក្សី ខឹម ងន (TCW-323) | សហព្រះរាជអាជ្ញា | ១៣.៤០ | ១៦.០០ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>សេចក្តីសម្រេចនៃការជំនួសចៅក្រមជំនុំជម្រះ</u>**

អង្គជំនុំជម្រះបានជូនដំណឹងទៅភាគីថា ចៅក្រម យូរ ឧត្តរា មិនអាចចូលរួមសវនាការថ្ងៃនេះបានទេ ហេតុដូច្នេះលោកចៅក្រម ធូ មណី នឹងជំនួសរហូតដល់លោកចៅក្រម យូរ ឧត្តរា មានវត្តមានវិញ ដោយអនុលោមតាមវិធាន ៧៩.៤។

**<u>សំណើសុំលះបង់សិទ្ធិចូលរួមដំណើរការសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ</u>**

ជនជាប់ចោទ អៀង សារី (សម្រាប់រយៈពេលពេញមួយថ្ងៃ) និង នួន ជា (សម្រាប់សវនាការពេលរសៀល) តាមរយៈមេធាវីរបស់ខ្លួន បានស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ តែសុំចូលរួមសវនាការពីបន្ទប់ឃុំខ្លួននៅខាងក្រោមបន្ទប់សវនាការ។ អង្គជំនុំជម្រះយល់ព្រមតាមការស្នើសុំ ។

**<u>ការកែតម្រូវកាលវិភាគនៃការធ្វើសវនាការ</u>**

ដោយសារតែសាក្សី សៅ សារុន មានបញ្ហាសុខភាព និងមានអាយុច្រើន មិនអាចចូលរួមសវនាការឱ្យបានពេញលេញ អង្គជំនុំជម្រះនឹងធ្វើសវនាការឆ្លាស់គ្នារវាងសាក្សី សៅ សារុន (TCW-604) និងសាក្សីដែលមានរហស្សនាម (TCW-323)។

**<u>ការតាំងសំណួរទៅសាក្សី សៅ សារុន</u>** <u>TCW-604</u>

សហព្រះរាជអាជ្ញាបន្តការសួរសំណួរទៅសាក្សី សៅ សារុន ។

**ភាពខុសគ្នាអំពីខ្សែអាត់សម្លេង និងកំណត់ហេតុស្តាប់ចម្លើយសាក្សី និងសំណើសុំធ្វើសេចក្តី**

**សន្និដ្ឋានផ្ទាល់មាត់**

មេធាវីការពារក្តី ខៀវ សំផន និងមេធាវីការពារក្តី នួន ជា បានធ្វើការកត់សម្គាល់អំពីភាពខុសគ្នានៃខ្សែអាត់សម្លេងបទសម្ភាសន៍របស់សាក្សី សៅ សារុន ដែលបានធ្វើជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត និងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃបទសម្ភាសន៍របស់សាក្សីនេះ។ មេធាវីបានលើកឡើងថា នៅក្នុងខ្សែអាត់សម្លេងនោះបានបង្ហាញថា ឈ្មោះហៅក្រៅរបស់លោក ខៀវ សំផន ត្រូវបានប្រាប់ដោយអ្នកស៊ើបអង្កេត មិនមែនសាក្សីជាអ្នកបញ្ជាក់ប្រាប់នោះទេ។ មេធាវីការពារក្តី បានស្នើសុំប្រតិចារិកផ្នែកពាក់ព័ន្ធនៃបទសម្ភាសន៍របស់សាក្សី សៅ សារុន។ អង្គជំនុំជម្រះបានចង្អុលបង្ហាញថា សំណើសុំទាក់ទងនឹងប្រតិចារិកនៃបទសម្ភាសន៍ និងការបកប្រែបទសម្ភាសន៍របស់សាក្សីនេះ គួរធ្វើជាលាយលក្ខណ៍អក្សរ ហើយបញ្ជាក់ឱ្យបានច្បាស់លាស់អំពីផ្នែកដែលពាក់ព័ន្ធសម្រាប់ការធ្វើប្រតិចារិក និងការបកប្រែភាសា។ អង្គជំនុំជម្រះបានទទួលយកសំណើសុំនេះ បន្ទាប់ពីមេធាវីការពារក្តីបានធ្វើការបញ្ជាក់អំពីអត្តសញ្ញាណនៃផ្នែកដែលពាក់ព័ន្ធ។

មេធាវីការពារក្តី នួន ជា ក៏បានស្នើសុំធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់លើបញ្ហាផ្សេងៗដែល មិនទាក់ទងនឹងសាក្សីដែលត្រូវបានស្តាប់ចម្លើយ ជាជាងការធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ។ អង្គជំនុំជម្រះបានលើកឡើងអំពីសេចក្តីសម្រេចមុនៗរបស់ខ្លួនថា សំណើផ្សេងៗដែលធ្វើក្រៅពីបញ្ហាទាក់ទង និងសំណុំរឿងនេះភាគីត្រូវធ្វើជាលាយលក្ខណ៍អក្សរ ព្រោះដើម្បីពន្លឿនកិច្ចដំណើរការនីតិវិធី។

**ការតាំងសំណួរទៅសាក្សី ខឹម ងន** TCW-323

អង្គជំនុំជម្រះបានតាំងសំណួរទៅសាក្សី ខឹម ងន អំពីជីវប្រវត្តរបស់សាក្សី បន្ទាប់មកសហព្រះរាជអាជ្ញាបានចាប់ផ្តើមតាំងសំណួរទៅសាក្សី។

| កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃកិច្ចរឹកតាង | | | | | | | |
|---|---|---|---|---|---|---|---|
| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in French |
| E3/367 | D125/167 | 00251435-00251441 00278692-00278697 00486008-00486013 | កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សារុន SĂO Sarun Written Record of Interview of SĂO Sarun Procès verbal d'audition de IM Aun អ៊ឹម អូន | P | 00251440, 00251441, 00251439 | 00278697, 00278696 | 00486013, 00486011 |
| E3/384 | D201/6 | 00345902-00345908 00348371-00348376 00354235-00354240 | កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី SAO Sarun សៅ សារុន ចុះថ្ងៃទី 30-06-2009 [Corrected 1] Written Record of Interview of SAO Sarun សៅ សារុន dated 30-06-2009 [Corrigé 2] Procès verbal d'audition de témoin SAO Sarun សៅ សារុន en date du 30-06-2009 | P | 00345904, 00345905, 00345903 | 00348373, 00348374, 00348372-73 | 00354237, 00354238, 00354236 |
| E3/1645 | D175/3.31 | 00230386-00230394 00809627-00809639 00809998-00810017 | ឈ្មោះអ្នកចូលថ្ងៃ២៣.១១.៧៧ Name who entered on 23.11.77 Nom des prisonniers arrivés le 23 novembre 1977 | P | | Numbers 128 and 129 on the list. | |
| E3/383 | D201/5 | 00345909-00345915 00350260-00350266 00361760-00361766 | កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី SAO Sarun សៅ សារុន ចុះថ្ងៃទី 29-06-2009 [Corrected 1] Written Record of Interview of SAO Sarun សៅ សារុន dated 29-06-2009 [Corrigé 1] Procès verbal d'audition de témoin SAO Sarun សៅ សារុន en date du 29-06-2009 | P | 00345913, 00345912, 00345911, 00345914 | 00350264, 00350263, 00350262, 00350265 | 00361764, 00361763, 00361762, 00361765 |
| E3/248 | D108/28.126 | 00021054-00021054 00324809-00324809 00631446-00631446 | ឧបសម្ព័ន្ធ១២៦: ទូរលេខ ៨៧ គោរពជូនបង មន្ទីរ ៨៧០ ជាទីគោរពស្នេហា អំពីប្រជាជនយួនរត់ចូលមកដីយើង Annex 126: Telegram 47 : To repected and beloved Brother Office 870 about Yuon 's people entry into our territory Annexe 126: Télégramme 47 : A l'attention du Frère de M. 870 bien-respecté et bien-aimé | P | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/1078 | D201/ 5.3 | 00020993-00020993<br>00361189-00361189<br>00623104-00623104 | ទូរលេខ លេខ 46 ចុះថ្ងៃទី 09-04-1978<br>Telegram No 46 dated 09-04-1978<br>Telegramme No 46 en date du 09-04-1978 | P | | | |
| E3/1646 | D175/ 3.15 | 00229930-00229930<br>00486391-00486391<br>00276980-00276980 | ផ្នែកតំបន់ ១០៥ (កង លាន)<br>Section Region 105 (កង លាន)<br>Section Region 105 (កង លាន) | P | | | |
| E3/156 | 21.11 3 | 00017027-00017027<br>00296220-00296220,<br>00185184-00185184<br>00531910-00531910 | ទូរលេខ ៥៤៖ គោរពជូន បង ជាទីគោរព អំពីសភាពការណ៍ពួកចារកម្មយួន<br>Telegram 54: To respected Brother about the situation of the Youns undercover agent<br>[Corrigé 1] Telegram 54: To respected Brother about the situation of the Youns undercover agent | P | | | |
| E3/1647 | D280/ 18 | 00368613-00368622<br>00375672-00375680<br>00426448-00426457 | កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹម ងន KHOEM Ngorn<br>Written Record of Interview of KHOEM Ngorn ខឹម ងន<br>Procès verbal d'audition de témoin KHOEM Ngorn ខឹម ងន | P | | 00375674 | |
| E3/1648 | 19.72 | 00020812-00020847,<br>00019490-00019490<br>00809951-00809997,<br>00183607-00183609,<br>00799177-00799177<br>00799091-00799124 | សំដីរបស់ ខឹម ងន ជាបុគ្គលិកក្រសួងការបរទេស ដោយ ផេង ពង្សរ៉ាស៊ី<br>DC-Cam Statement of KHOEM Ngon<br>Déclaration de KHOEM Ngorn (DC-Cam) | P | 00019490 | 00797177 | |

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

- សេចក្តីសម្រេចក្នុងការជំនួសចៅក្រម យូរ ឧត្តរា ដោយចៅក្រម ធូ មណី រហូតដល់គាត់មានវត្តមានវិញ អនុលោមតាមវិធាន ៧៩.៤។
- សេចក្តីសម្រេចទទួលយកសំណើសុំធ្វើប្រតិចារិកបទសម្ភាសន៍របស់សាក្សី សៅ សារុន នៅផ្នែកដែលពាក់ព័ន្ធ ដូចចង្អុលបង្ហាញដោយមេធាវីការពារក្តី ខៀវ សំផន។

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតឱ្យជនជាប់ចោទ អៀង សារី (០៩.០៣) និង នួន ជា (១២.០៥) ចូលរួមដំណើរការសវនាការពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ និងបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់រង់ចាំ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទទាំងពីរត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនិងកំណត់ហេតុនេះ)។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី, នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវសំផន ត្រឡប់មកកាន់បន្ទប់សវនាការវិញឱ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១២។ ដោយឡែកជនជាប់ចោទ អៀង សារី ឱ្យនាំខ្លួនមកបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការ ប្រសិនបើជនជាប់ចោទបានស្នើសុំលះបង់សិទ្ធិក្នុងការមានវត្តមាននៅក្នុងបន្ទប់សវនាការ។
- បង្គាប់ឱ្យនាំសាក្សី សៅ សារុន ទៅកាន់កន្លែងស្នាក់នៅរបស់គាត់ និងនាំគាត់ត្រឡប់មកបន្ទប់សវនាការឱ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១២។
- បង្គាប់ឱ្យនាំសាក្សី ខឹម ងួន ទៅកាន់កន្លែងស្នាក់នៅរបស់គាត់ និងនាំគាត់ត្រឡប់មកបន្ទប់សវនាការឱ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១២។

| <u>កាលបរិច្ឆេទបន្តសវនាការ៖</u> |
|---|
| សវនាការនឹងបន្តទៅថ្ងៃ ចន្ទ ទី ១១ ខែ មិថុនា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

**សែ គុលធុន្នី** Matteo CRIPPA